ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 03 / 2016
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, សហចៅក្រមស៊ើបអង្កេត**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់ នួន ជា តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកសារទូរលេខតាមផ្លូវទូតចំនួន ១១**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់មេធាវីការពារក្តី នួន ជា ដែលបានដាក់កាលពីថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ សុំឲ្យទទួលយកធ្វើជាឯកសារភ័ស្តុតាងនូវសារទូរលេខតាមផ្លូវទូតចំនួន ១១ ដោយអនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង ("សំណើសុំ" ឯកសារ E383 និង ឧបសម្ព័ន្ធ ១ ដល់ ១១)។ សារទូរលេខតាមផ្លូវទូត ១ ដល់ ២ ត្រូវបានបញ្ជូនដោយស្ថានទូតអូស្ត្រាលី ប្រចាំទីក្រុងហាណូយ (ចុះថ្ងៃទី ០៨ ខែ ឧសភា និង ថ្ងៃទី ២០ ខែសីហា ឆ្នាំ ១៩៧៥), សារទូរលេខ ៣ ដល់ ៧ និង ៩ ត្រូវបានបញ្ជូនដោយស្ថានទូតសហរដ្ឋអាមេរិក ប្រចាំទីក្រុងបាងកក (ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៧៦ និង ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨), សារទូរលេខ ០៨ និង ១០ ត្រូវបានបញ្ជូនដោយស្ថានទូតសហរដ្ឋអាមេរិក ប្រចាំ ទីក្រុងប៉ារីស (ចុះថ្ងៃទី ០៨ និង ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៧៦) និង សារទូរលេខ ១១ ដែលត្រូវបានបញ្ជូនដោយស្ថានទូតសហរដ្ឋអាមេរិក ប្រចាំទីក្រុងភ្នំពេញ (ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២) (សំណើកថាខណ្ឌ ៤, ១៦ ដល់ ២៥)។ ក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងថា សារទូរលេខទាំង ១១ បាន

បំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង។ សារទូរលេខមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ដោយសារតែសារទូរលេខបានផ្តល់នូវភស្តុតាងអំពីការបោសសម្អាតផ្ទៃក្នុង និង មន្ទីរសន្តិសុខ ស-២១, អត្ថិភាព និង លក្ខណៈនៃជម្លោះប្រដាប់អាវុធរវាងវៀតណាម និង កម្ពុជាប្រជាធិបតេយ្យ នៅក្នុងអំឡុងពេលវេលាពាក់ព័ន្ធ , រចនាសម្ព័ន្ធរដ្ឋបាល និង យោធារបស់កម្ពុជាប្រជាធិបតេយ្យ និង អំពីតួនាទីរបស់ នួន ជា (សំណើសុំ កថាខណ្ឌ ១៣ ដល់ ១៤, ៣១ ដល់ ៣៧)។ បន្ថែមពីលើនេះ មេធាវីការពារក្តី នួន ជា បានលើកឡើងថា សារទូរលេខទាំងនេះអាចជឿជាក់បាន៖ សារទូរលេខ ១ ដល់ ២ មានត្រាផ្លូវការរបស់ក្រសួងការបរទេសអូស្ត្រាលី ហត្ថលេខារបស់ម្ចាស់អត្ថបទ និង មានកំណត់សម្គាល់សរសេរដោយដៃផ្សេងៗទៀត (សំណើសុំ កថាខណ្ឌ ១៥)។ សារទូរលេខ ៣ ដល់ ១០ ត្រូវបានទាញចេញពីគេហទំព័រផ្លូវការរបស់បណ្ណសារដ្ឋានជាតិសហរដ្ឋអាមេរិក (សំណើសុំ កថាខណ្ឌ ៣៨) និង សារទូរលេខ ១១ មាននូវព័ត៌មានដែលត្រូវបានបញ្ជាក់ដោយភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង ហើយត្រូវបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ (សំណើសុំ កថាខណ្ឌ ៣៩)។ ជាចុងក្រោយ មេធាវីការពារក្តី នួន ជា បានលើកឡើងថា សារទូរលេខមិនអាចត្រូវបានរកឃើញនៅមុនពេលចាប់ផ្តើមសវនាការនៃសំណុំរឿង ០០២/០២ ទោះបីជាខិតខំប្រឹងប្រែងដោយសមស្របក៏ដោយ។ អត្ថិភាពរបស់សារទូរលេខ ស្ថានទូតអូស្ត្រាលីត្រូវបានរកឃើញតាមរយៈអត្ថបទសារព័ត៌មានមួយនៅក្នុងខែ តុលា ឆ្នាំ ២០១៥ ចំណែកសារទូរលេខសហរដ្ឋអាមេរិក គឺមេធាវីការពារក្តីបានដឹងចន្លោះពីថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣ ដល់ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០១៤ ហើយមិនអាចធ្វើការកំណត់អត្តសញ្ញាណបាននៅមុនពេលវេលានេះឡើយ ដោយសារតែការខ្វះខាតធនធានរបស់មេធាវីការពារក្តី។ មួយវិញទៀត ដោយសារសារទូរលេខទាំងនេះគឺជាផ្នែកនៃទិន្នន័យដែលរួមមានសារទូរលេខតាមផ្លូវទូតជាងពីរលាន (សំណើសុំ កថាខណ្ឌ ៩, ២៨)។

២. មេធាវីការពារក្តី ខៀវ សំផន បានគាំទ្រដល់សំណើសុំ (ឯកសារ E383/1, កថាខណ្ឌ ១០)។ មេធាវីការពារក្តីក៏បានលើកឡើងផងដែរថា ដើម្បីផលប្រយោជន៍យុត្តិធម៌ ត្រូវធ្វើការវាយតម្លៃសារទូរលេខទាំង១១នេះ រួមជាមួយឯកសារដែលមានចំណងជើងថា “ខ្មែរក្រហម និង ជនកុម្មុយនីស្តវៀតណាម៖ ប្រវត្តិនៃទំនាក់ទំនង ដូចមានរៀបរាប់នៅក្នុងបណ្ណសារដ្ឋានសូវៀត” (ឯកសារ E383/1, កថាខណ្ឌ ៨)។ ការសិក្សាដែលធ្វើឡើងដោយ Dimitry Mosyakov ត្រូវបានទទួលយករួចហើយ ហើយត្រូវបានផ្តល់នូវលេខឯកសារ E3/9644 (ឯកសារ E347/1, កថាខណ្ឌ ៦)។ ការសិក្សានោះបានផ្តល់នូវភស្តុតាងស្តីពីជម្លោះ

ប្រដាប់អាវុធរវាងវៀតណាម និង កម្ពុជាប្រជាធិបតេយ្យ (ឯកសារ E347/1,កថាខណ្ឌ ៦)។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់ចម្លើយតបណាមួយទៅនឹងសំណើសុំឡើយ។

៣. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកនៅដំណាក់កាលណាមួយក៏បានក្នុងពេលជំនុំជម្រះ នូវរាល់ភស្តុតាងដែលអាចនាំទៅដល់ការស្វែងរកការពិត ប្រសិនបើភស្តុតាងនោះបានបំពេញតាមបទដ្ឋានបឋមនៃភាពពាក់ព័ន្ធ ភាពអាច ជឿជាក់បាន និង យថាភាព ដូចដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសម្រេចទៅលើខ្លឹមសារនៃសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យក្នុងវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលតម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវស្នើសុំតាមរយៈសារណាដែលមានសំអាងហេតុ។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថាភស្តុតាងដែលបានស្នើសុំ មិនមានអត្ថិភាពមុនពេលបើកការជំនុំជម្រះ ឬ មិនអាចរកបានទោះមានការខិតខំប្រឹងប្រែងក៏ដោយ។ ប៉ុន្តែនៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកជាឯកសារភស្តុតាង ដែលនិយាយឱ្យសាមញ្ញទៅមិនបានបំពេញបានតាមលក្ខណៈវិនិច្ឆ័យនេះឡើយ ដែលក្នុងនោះរួមមានករណីដែលភស្តុតាងពាក់ព័ន្ធខ្លាំងជាមួយសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និងក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យវាយតម្លៃរួមគ្នាលើប្រភពនៃភស្តុតាង និង ក្នុងករណីដែលឯកសារដែលបានស្នើគឺជាឯកសារដោះបន្ទុក ហើយតម្រូវឱ្យវាយតម្លៃដើម្បីចៀសវាងនូវភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌ (ឯកសារ E276/2, កថាខណ្ឌ ២ យោងទៅរកឯកសារ E190 និង ឯកសារ E172/24/5/1។ ឯកសារ E260, កថាខណ្ឌ ៥)។

៤. អង្គជំនុំជម្រះកត់សម្គាល់ថា សារទូរលេខទាំងនេះ ជាឯកសារសម្ងាត់នៅពេលបញ្ជូនចេញ ហើយត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមមធ្យោបាយផ្សេងៗគ្នា និង ក្នុងកាលបរិច្ឆេទខុសៗគ្នា។ សារទូរលេខ ១ និង ២ ហាក់ដូចជាត្រូវបានផ្លាស់ប្តូរការកំណត់ប្រភេទចំណាត់ថ្នាក់ឯកសារនៅក្នុងឆ្នាំ ២០១១ ហើយត្រូវបានផ្តល់ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅខែ កញ្ញា ឆ្នាំ ២០១៥។ សារទូរលេខទាំងពីរនេះត្រូវបានរាយការណ៍នៅក្នុងអត្ថបទសារព័ត៌មានមួយ នៅក្នុងខែ តុលា ឆ្នាំ ២០១៥ ដែលនៅពេលនោះទើបមេធាវីការពារក្តីបានដឹងអំពីអត្ថិភាពនៃសារទូរលេខទាំងនេះ (សំណើសុំកថាខណ្ឌ ៩)។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើសុំរបស់មេធាវីការពារក្តីត្រូវបានដាក់ទាន់ពេលវេលា។ អង្គជំនុំជម្រះយល់ឃើញថា សារទូរលេខទាំងពីរនេះផ្តល់នូវភស្តុតាងតាមសម័យកាលដោយ

និយាយពាក់ព័ន្ធនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងការរៀបរាប់តាមសម័យកាលអំពីរចនាសម្ព័ន្ធកងទ័ព និង រដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ។ សារទូរលេខ ១ និង ២ គឺជាឯកសារត្រឹមត្រូវមានយថាភាព ដូចដែលបានបង្ហាញតាមរយៈត្រារបស់ក្រសួងការបរទេសអូស្ត្រាលី និង ចុះហត្ថលេខាដោយលេខាទីមួយ។ ដូចនេះ ការទទួលយកសារទូរលេខទាំងនេះ អាចនាំទៅដល់ការស្វែងរកការពិតបាន។

៥. សារទូរលេខ ៣ ដល់ ១០ ត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយបណ្ណាសារដ្ឋានជាតិសហរដ្ឋអាមេរិក៖ គឺសារទូរលេខ ៣ ដល់ ៦ ត្រូវបានផ្សព្វផ្សាយនៅក្នុងខែ មីនា ឆ្នាំ ២០១៤, សារ-ទូរលេខ ៧ នៅក្នុងឆ្នាំ ២០០៩ និង សារទូរលេខ ៨ ដល់ ១០ នៅក្នុងឆ្នាំ ២០០៦ (សំណើសុំ កថាខណ្ឌ ២៧ ដល់ ២៨)។ បើទោះបីជាកត់សម្គាល់ឃើញថា សារ-ទូរលេខ ៧ ដល់ ១០ អាចរកបានមុនពេលចាប់ផ្តើមសវនាការក៏ដោយ តែអង្គជំនុំជម្រះបានកត់សម្គាល់ថា សារទូរលេខទាំងនេះគឺជាផ្នែកនៃទិន្នន័យ ដែលមានប្រហែល ១០ ពាន់លានទំព័រ និង ប្រហែលជាង២លានសារទូរលេខ ចាប់ពីរយៈពេលដែលពាក់ព័ន្ធនោះ (សំណើសុំ កថាខណ្ឌ ២៨)។ មេធាវី ការពារក្តី នួន ជា បានដឹងអំពីអត្ថិភាពនៃសារ-ទូរលេខទាំងនេះ បន្ទាប់ពីឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយនៅលើ WikiLeaks ចន្លោះពីថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣ ដល់ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ គឺក្រោយពីពេលចាប់ផ្តើមសវនាការ (សំណើសុំ កថាខណ្ឌ ២៨)។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានកត់សម្គាល់ថា កាតព្វកិច្ចនៃការខិតខំប្រឹងប្រែងដោយសមស្រប គឺជាកាតព្វកិច្ចមួយដែលត្រូវអនុវត្តជាប្រចាំ ហើយភាគីចាំបាច់ត្រូវស្នើសុំឱ្យទទួលយកធ្វើជាឯកសារភស្តុតាងនូវបណ្តាសម្ភារៈទាំងឡាយណាដែលភាគីមានបំណងពឹងផ្អែកឱ្យបានឆាប់រហ័ស ក្រោយពីសម្ភារៈទាំងនោះត្រូវបានរកឃើញ (ឯកសារ E319/30/1, កថាខណ្ឌ ៣)។ អង្គជំនុំជម្រះយល់ឃើញថា ការអះអាងរបស់មេធាវីការពារក្តី នួន ជា ដែលថា មានការខ្វះខាតផ្នែកធនធានមិនអាចជាយុត្តិកម្មសម្រាប់ការពន្យាពេល ២០ ខែ ក្រោយពេលដែលសារទូរលេខទាំងនេះ តាមពិតអាចស្វែងរកបាននៅលើគេហទំព័រ WikiLeaks មុនពេលដាក់សំណើរបស់ខ្លួនសុំឱ្យទទួលយកសារទូរលេខទាំងនេះឡើយ។ ហេតុដូច្នេះ សំណើសុំនេះ គឺជាសំណើសុំដែលបានដាក់យឺតពេល។

៦. ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះពិចារណាថា សារទូរលេខ ៣ ដល់ ១០ ពីស្ថានទូតសហ-រដ្ឋអាមេរិកចំនួនពីរ បានផ្តល់នូវភស្តុតាងតាមសម័យកាល ទាក់ទងអត្ថិភាពនៃជម្លោះប្រដាប់អាវុធ រវាងវៀតណាម និង កម្ពុជាប្រជាធិបតេយ្យ នៅក្នុងអំឡុងរយៈពេលពាក់ព័ន្ធ

នៃការចោទប្រកាន់ ហើយឯកសារទាំងនេះទាក់ទងយ៉ាងជិតស្និទ្ធជាមួយសម្ភារៈដទៃទៀត ដែលត្រូវបានទទួលយកជាឯកសារភ័ស្តុតាង រួមបញ្ចូលទាំងសារទូរលេខ ១ និង ២ មកពីស្ថានទូតអូស្ត្រាលី ដែលដូច្នេះហើយទើបប្រយោជន៍យុត្តិធម៌ គាំទ្រដល់ការទទួលយកសារទូរលេខទាំងអស់នេះរួមគ្នា។ បន្ថែមលើនេះ សារទូរលេខទាំងអស់នេះមានយថាភាព ដោយគិតដល់ទិន្នន័យបន្ទាប់បន្សំរបស់សារទូរលេខទាំងនោះផងដែរ (អ្នកបញ្ជូន, អ្នកទទួល, ចំណាត់ថ្នាក់ឯកសារ និង កាលបរិច្ឆេទនៃការបញ្ជូន) ព្រមទាំងប្រភពផ្លូវការដែលឯកសារទាំងនេះត្រូវបានទទួល (សំណើសុំ កថាខណ្ឌ ៣៨ ដល់ ៣៩)។ ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ថា មិនមានភាគីណាមួយជំទាស់លើការទទួលយកធ្វើជាឯកសារភ័ស្តុតាងនូវសារទូរលេខទាំងនេះឡើយ។ អាស្រ័យដូចបានរៀបរាប់ខាងលើ សារទូរលេខទាំងអស់នេះអាចនាំទៅដល់ការស្វែងរកការពិត ហេតុដូច្នេះទើបសារទូរលេខទាំងនេះអាចទទួលយកបាន។

៧. ជាចុងក្រោយអង្គជំនុំជម្រះយល់ឃើញថា សំណើសុំឱ្យទទួលយកសារទូរលេខ ១១ គឺធ្វើឡើងមិនទាន់ពេលវេលាឡើយ។ សារទូរលេខនេះអាចរកបានចាប់តាំងពីពេលផ្សព្វផ្សាយនៅលើ WikiLeaks កាលពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១១ មកម្ល៉េះ ហើយមេធាវីការពារក្តី នួន ជា មិនបានបង្ហាញពីអត្ថិភាពនៃឧបសគ្គណាមួយដែលរារាំងមិនឱ្យរកឃើញបានឆាប់នោះឡើយ។ អង្គជំនុំជម្រះក៏បានពិចារណាផងដែរថា ព័ត៌មានដែលមាននៅក្នុងសារទូរលេខ គឺមិនពាក់ព័ន្ធជាមួយសំណុំរឿង ០០២/០២ ឡើយ៖ សារទូរលេខនេះមិនមែនជាឯកសារតាមសម័យកាល ពីរបបកម្ពុជាប្រជាធិបតេយ្យឡើយ ហើយផ្តល់ព័ត៌មានអំពី ហោ ណាំហុង ដែលបច្ចុប្បន្នគឺជាសមាជិករាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអំពីតួនាទីរបស់គាត់នៅជំរុំបឹងត្របែក ដែលពាក់ព័ន្ធបន្តិចបន្តួចជាមួយវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០២។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចច្រានចោលសំណើសុំទទួលយកធ្វើជាឯកសារភ័ស្តុតាងនូវសារទូរលេខនេះ។

៨. អាស្រ័យហេតុនេះ សំណើសុំត្រូវបានអនុញ្ញាតចំពោះសារទូរលេខ ១ ដល់ ១០ ហើយអង្គជំនុំជម្រះនឹងផ្តល់នូវលេខ E3 ដល់សារទូរលេខទាំងដប់ ដូចបានបញ្ជាក់ច្បាស់នៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។ នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E383។